អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៧ មិថុនា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណើសុំនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣

នៅក្នុងដីកាសម្រេចមួយដែលមានសម្អាងហេតុ ដែលធ្វើឡើងនៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានបដិសេធមិនទទួលយកសំណើសុំពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ រួមទាំងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួន ៣ ទៀត ដែលដាក់ដោយសហព្រះអាជ្ញាតែម្នាក់ឯង ដោយហេតុថាការដាក់ឯកសារទាំងនោះត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវតាមទម្រង់ច្បាប់ ។

បន្ទាប់ពីបានពិនិត្យលើកម្រងបទដ្ឋានគតិយុត្ត និងវិធានផ្ទៃក្នុងដែលអនុវត្តចំពោះដំណើរការនីតិវិធីនៅ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វិធានផ្ទៃក្នុងមិនមានទុកចន្លោះណាមួយសម្រាប់ឱ្យសហព្រះរាជអាជ្ញាមួយរូប អាចធ្វើកិច្ចជាលក្ខណៈបុគ្គលបានឡើយ លើកលែងតែមានសេចក្តីសម្រេចផ្ទេរអំណាចដែលត្រូវធ្វើឡើងដោយអនុលោមតាមវិធាន ១៣(៣) នៃវិធានផ្ទៃក្នុង ឬកំណត់ហេតុនៃការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាដែលធ្វើឡើងដោយស្របនឹងវិធាន ៧១(១) ។

ដោយហេតុថា ទាំងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ សុទ្ធតែបានបញ្ជាក់ថា មិនមានសេចក្តីសម្រេចផ្ទេរអំណាចណាមួយ ឬកំណត់ហេតុនៃការខ្វែងយោបល់ណាមួយត្រូវបានធ្វើឡើង សហចៅក្រមស៊ើបអង្កេតបានសម្រេចបដិសេធមិនទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយហេតុផលថាសំណើសុំទាំងនោះត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ប៉ុន្តែ ដោយអនុលោមតាមវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតសម្រេចទទួលស្គាល់សុពលភាពនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលក្នុងអំឡុងពេល ៣ សប្តាហ៍ បន្ទាប់ពីពេលវេលាកំណត់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ បានផុតរលត់ ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh